F10

F10

ជលផល

UNDP

Technology of Tilapia seed production

# បច្ចេកទេស
# ផលិតពូជត្រីទីឡាព្យា



រៀបរៀងដោយ :
គណៈកម្មការអភិវឌ្ឍន៍វារីវប្បកម្មខេត្តតំបន់ពាយ័ព្យ
ឧបត្ថម្ភដោយអង្គការ UNDP / UNOPS / CARERE
1998

# បច្ចេកទេសផលិតពូជត្រីទីឡាព្យា

## មាតិការឿង


អារម្ភកថា ............................ ១

១-សំនាំដើម ............................ ៣

២-សណ្ឋានខាងក្រៅនៃត្រីទីឡាព្យានីឡូទីកា ..... ៤

៣-ការរៀបចំស្រះ ............................ ៦

ក-ស្រះថ្មី ............................ ៧

ខ-ស្រះចាស់ ............................ ៨

៤-ការដាក់ត្រីមេពូជ ............................ ១០

៥-ការផ្តល់ចំណី ............................ ១៣

៦-ការស្ទូចឈាស់ ............................ ១៥

៧-ការបន្តពូជ ............................ ១៧

ក-លក្ខណៈសំគាល់ត្រីញី ឈ្មោល ... ១៧

ខ-អាយុបន្តពូជ ............................ ១៨

គ-វដ្ដសន្ដពូជ ..................... ១៩

៨-លក្ខណៈបន្ដពូជ ..................... ២០

៩-ការប្រមូល និង ផ្សាំកូនត្រី ............ ២២

១០-បញ្ហាសំខាន់ ៗ ដែលជួបប្រទះ ...... ២៤

១១-ការគ្រប់គ្រង និង ថែទាំស្រះ ........ ២៥

១២-ការប្រមូលផល ..................... ២៨

-ឯកសារយោង

-បញ្ជីរាយនាមឈ្មោះគណៈកម្មការ


# អារម្ភកថា

ត្រីទីឡាព្យាជាប្រភេទត្រីសាយកូន ដែលអាចបន្ដពូជខ្លួនឯងនៅតាមស្រះចិញ្ចឹម ។ ត្រីចិញ្ចឹមមាន ការលូតលាស់ឆាប់រហ័សនិងងាយចិញ្ចឹមហើយអាចប្រមូលផលបន្ទាប់ពីការចិញ្ចឹមបានរយៈពេល ៦-៨ ខែ ។

ត្រីទីឡាព្យាជាប្រភេទត្រីត្រូវបានគេទទួលស្គាល់ថា ជាត្រីអាចផ្ដល់ប្រាក់ចំណូលច្រើនសំរាប់គ្រួសារកសិករ ។ជាក់ស្ដែងនៅខេត្តតំបន់ពាយ័ព្យយើងនេះ ប្រជាជនកំពុងពេញនិយមចិញ្ចឹមត្រីយ៉ាងផុលផុសបំផុត។

ក្នុងទិសដៅជួយបង្កើនផលិតផលត្រីដល់ប្រជាកសិករនៅតំបន់ជនបទ គណៈកម្មការអភិវឌ្ឍន៍ភាវីវប្បកម្ម ខេត្តតំបន់ពាយ័ព្យដោយមានការជួយឧបត្ថម្ភពីអង្គការ CARERE បាន

ផ្តួចផ្តើមគំនិតជាយុទ្ធសាស្ត្រមួយប្រចាំតំបន់ពាយ័ព្យ សំដៅលើការអភិវឌ្ឍន៍វារីវប្បកម្មនៅតាមស្រះ ស្រែ នៅតាមតំបន់គោលដៅ នានាទូទាំងខេត្តក្នុងគោលបំណងជួយលើកស្ទួយកំរិតជីវភាពប្រជាជន នៅតំបន់ជនបទអោយប្រសើរឡើង ។

គណៈកម្មការយើងខ្ញុំបានខិតខំចងក្រងនូវសៀវភៅបច្ចេកទេស ផលិតពូជត្រីទីឡាព្យានេះឡើងសំរាប់ជាទុន និង ជាបទពិសោធន៍ដល់ប្រជាកសិករ ដែលមានបំណងចិញ្ចឹមត្រីអោយមានការអភិវឌ្ឍន៍ឡើង សំរាប់ជួយដោះស្រាយម្ហូបអាហារតាមគ្រួសារបានមួយកំរិត ។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះ ពិត[illegible]ម ចំណែកជាវិភាគទានដល់ប្រជាកសិករក្នុង[illegible] ភាពអភិវឌ្ឍន៍វារីវប្បកម្ម នៅតំបន់ជនបទ[illegible]

**រៀបរៀងដោយ**

**គណៈកម្មការអភិវឌ្ឍន៍វារីវប្បកម្មខេត្តតំបន់[illegible]**



**១-សំគាល់**

ត្រី *ទីឡាព្យាទីឡូទីកា* មានប្រភពដើមនៅទ្វីបអាហ្វ្រិកខាងកើតនិងខាងជើងជាពិសេសនៅតាមដងទន្លេ *នីល* ។ នៅសតវត្សទី២០ គេបានយកត្រីនេះ មកចិញ្ចឹមជាច្រើននៅលើសកលលោក ហើយទទួលបានទិន្នផលខ្ពស់នៅលើប្រទេសក្តៅ និង ក្តៅល្មម ។

*ត្រីទីឡាព្យាទីឡូទីកា* ជាប្រភេទត្រីដែលអាចរស់នៅក្នុងទឹកសាប ទឹកប្រៃ ឬ ទឹកភ្លាវក៏បាន ក្នុងកំហាប់អំបិលរហូតដល់ ៣៦ភាគពាន់ ។ នៅក្នុងធម្មជាតិគេជួបប្រទះ ត្រីមានរស់នៅក្នុង ទន្លេ បឹងបួរ ឬ នៅតំបន់ផ្សេងៗទៀតជាច្រើន ព្រោះជាប្រភេទត្រីអាចធន់នឹងលក្ខខ័ណ្ឌធម្មជាតិ ដូចជាតំបន់ដែលមានអុកស៊ីសែនរលាយក្នុងទឹកតិច ឬ សីតុណ្ហភាពខ្ពស់លើសពី២៤-២៨អង្សាសេ។

តាមការសិក្សាស្រាវជ្រាវ បានបញ្ជាក់ថាត្រីទីឡាព្យាមានរហូតដល់ជាង ១០០ប្រភេទ

ក្នុងនោះមាន៦ប្រភេទសំខាន់ៗត្រូវបានគេនិយមចិញ្ចឹមនៅក្នុងស្រះ ។ ដោយឡែកនៅប្រទេសកម្ពុជាយើងត្រីទីឡាព្យា បាននាំចូលមកចិញ្ចឹមមានតែពូជត្រី *ទីឡាព្យានីឡូទីកា* និង *ទីឡាព្យា ម៉ូសំប៊ីកា* ។

**២-សណ្ឋានខាងក្រៅនៃត្រីទីឡាព្យានីឡូទីកា**

ត្រីទីឡាព្យាមានដងខ្លួនរាងសំប៉ែតបញ្ឈរ



**ត្រីទីឡាព្យានីឡូទីកា**



និងគ្របដណ្តប់ដោយស្រកា ។ ទំរង់មាត់មានរង្វះ និងក្រអូមមាត់ធំល្មម បើប្រៀបធៀបទៅនឹងប្រភេទត្រីដទៃទៀត ដែលជាប្រភេទត្រីក្នុងស្រុកដូចជាត្រីកន្ត្រប់ ត្រីក្រាញ់ ត្រីកន្ធរ ។

ក្បាលមានរាងត្រីកោណ ចំពោះត្រីមេក្បាលរាងផតពីលើបន្តិច ភ្នែកធំ មូល ប៉ោងបន្តិច និង មានដងខ្លួនតូចជាងត្រីឈ្មោល ។

ពណ៌សម្បុរត្រីមាន លក្ខណៈបន្ទាប់បន្សំសំរាប់សំគាល់ប្រភេទ និងជាលក្ខណៈធម្មជាតិសំរាប់បំបាំងខ្លួនពីសត្វចង្រៃក្នុងមជ្ឈដ្ឋានទឹក ។ ត្រីទីឡាព្យានីឡូទីកា ផ្នែកខ្នងមានពណ៌ក្រម៉ៅឆ្នូត និងផ្នែកពោះមានពណ៌សព្រោក់ នៅតាមបណ្តោយខ្លួនមានឆ្នូតទទឹងក្រមៅ ។ ចំពោះត្រីនៅតូចមានពណ៌ក្រមៅស្រគាំ និង ឆ្នូតទទឹងក្រមៅលេចច្បាស់ ។

ចំពោះត្រីពេញវ័យ ផ្នែកខាងលើក្បាល**មានពណ៌**ក្រមៅត្នោត ផ្នែកខាងក្រោមមាន**ពណ៌ស**ព្រោក់ នៅលើដងខ្លួនផ្នែកខាងខ្នងមាន

ពណ៌ក្រមៅស្វៃ ផ្នែកពោះពណ៌សប្រាក់និងនៅតាមបណ្តោយខ្លួនមានឆ្នូតទទឹងខៀវ ។ ចំពោះត្រីឈ្មោល មានពណ៌សម្បុរល្អស្រស់ជាងត្រីមេ ដោយព្រុយខ្នង និង ព្រុយកន្ទុយមានពណ៌ក្រហមព្រឿង ។ ហើយនៅខាងចុងព្រុយមានឆ្នូតខៀវ ។

## ៣-ការរៀបចំស្រះ

ស្រះមានទំហំសមស្របពី ១០១-៥០០$ម^2$ ជំរៅជាមធ្យម ១,២០-២,០០ម និង២,៥០-៣,០០ម ក្នុងករណីគ្មានប្រភពទឹកនៅជិត ។




ស្រះផលិតពូជត្រីទីឡាព្យា



ភ្លឺស្រះត្រូវមានចំងាយយ៉ាងតិច១ម៉ែត្រពីមាត់ស្រះនិងមានកំពស់ខ្ពស់អាចការពារទឹកមិនអោយហូរចេញ ចូលបាន ។ រៀបចំដាំស្មៅពីលើភ្លឺ និង ជើងទេរស្រះ ។ បាតស្រះត្រូវមានផ្ទៃជម្រាលបន្តិច និង មានកំរាស់បាតភក់ជាមធ្យម ពី ៥- ១០ សម ។

**ក.ស្រះថ្មី** ( ទំហំ ១០០ $ម^2$ )

-ជីគីមី :អ៊ុយរ៉េចំនួន ១-២គក្រ និង ដេ អា ប៉េ ចំនួន ០,៥០-១,០០គក្រ

-កំបោរស ចំនួន ៥-១០ គក្រ

-ជីបៃតង ឬ ជីរុក្ខជាតិ( ស្លឹកទន្ទ្រាន ខែត អង្កាជី ) ចំនួន ៣០-៣៥គក្រ ។

-ជីលាមកគោក្របីពី ៣០-៤០គក្រ ។ ម្យ៉ាងទៀតអាចប្រើលាមកមាន់ ឬ ទា ចំនួន៦ គក្រ ។

បន្ទាប់ពីដាក់ជីបាន ៧-១០ ថ្ងៃមកទើបដាក់លែងកូនត្រី ។




**ការប្រើប្រាស់ជី**

**ខ.ស្រះចាស់**

សំអាតបាតស្រះ ដោយទុកល្បាប់ភក់ពី ៥-១០សម ។ បាចកំបោរសពី ៥-៧ គក្រ ក្នុង ១០០ $ម^{២}$ រួចហាលបាតស្រះរយៈពេល ៣-៧ ថ្ងៃ ។

បើពុំអាចបូមទឹកស្រះចាស់ ចេញទេនោះ គប្បីបង្កើនបរិមាណកំបោរ រហូតដល់ ១០-១៣ គក្រ/១០០$ម^{២}$ ។ ការដាក់ជីស្រះត្រូវ



មានបរិមាណតិចជាង ការដាក់ជីចំពោះស្រះថ្មី ។



**ការដាក់ជីស្រះ**

ពេលបូមទឹកបញ្ចូលស្រះ ត្រូវប្រើសំណាញ់ ការពារកុំអោយត្រីកាចចូលក្នុងស្រះបាន។

បើទឹកស្រះល្អក់គួរប្រើ ចំបើង ចក កំភ្លោក ផេះ ។ល។ ទៅតាមលទ្ធភាពដែលមាននៅតាមមូលដ្ឋាន ។







## ៤-ការដាក់ត្រីចិញ្ចឹម

ចំពោះស្រះផលិតពូជត្រី ដាក់ចិញ្ចឹមក្នុងអាត្រា ឈ្មោល១ក្បាល : ញី ២ ក្បាល ។ ដូច្នេះស្រះ ១០០ម$^{២}$ អាចដាក់ត្រីមេបានចំនួន ១៤ក្បាល និង ឈ្មោលចំនួន ៧ក្បាល ឬ ត្រីមេ ១៥ ក្បាល និង ត្រី



ត្រីឈ្មោល ៥ក្បាល ។




ត្រីមេពូជ[illegible] ១ ក្បាល ក្នុងផ្ទៃស្រះ [illegible]អាយត្រីមានទីធ្លាគ្រប់គ្រាន់[illegible] មានចំណីធម្មជាតិគ្រប់[illegible]



**ការដាក់កូនត្រីចិញ្ចឹម**

តាមធម្មតាយើងមិនអាចចាប់កូនត្រីមេ្សា អស់ពីក្នុងស្រះនោះទេ កូនត្រីដែលមាននៅសល់ក្នុងស្រះផលិតពូជ បានលូតលាស់ធំក្លាយជាមេពូជបន្ត ។

ស្រះផលិតកូនត្រីពូជត្រូវបង្ហូរ ឬបូមទឹកចេញ និងសំអាត ស្រះជារៀងរាល់ឆ្នាំ ហើយត្រីមេពូជ ត្រូវតែពិនិត្យមើលសុខភាព និង



គុណភាព ។ បើត្រីអន់គុណភាពត្រូវផ្លាស់ប្តូរចេញ ។ មិនតែប៉ុណ្ណោះយើងត្រូវផ្លាស់ប្តូរមេពូជ ពីស្រះមួយទៅស្រះមួយ ឬ ពី តំបន់មួយទៅតំបន់មួយ ដើម្បីអោយត្រីមានការលូតលាស់បានល្អ ។

**៥-ការផ្តល់ចំណី**

ត្រីទីឡាព្យានីឡូទីកាជាប្រភេទត្រីស៊ីចំណី



**ការដាក់ចំណីត្រី**

ចំរុះ ក្រៅពីចំណីធម្មជាតិ ដែលកើតមាននៅក្នុងស្រះ មានផ្តល់ចំណីបន្ថែមទៀត ដូចជា កន្ទក់ ម្សៅត្រី បន្លែស្រស់ ចក ត្រកួន ក្នុងបរិមាណ ៣-៥ ភាគរយនៃទំងន់ត្រី។

ការផ្តល់ចំណីបន្ថែមត្រូវដាក់ក្នុងកំរិតមួយ ដែលត្រីអាចស៊ីអស់ក្នុងរយៈពេល ១៥-៣០ នាទី ដើម្បីបន្ថយការបាត់បង់ចំណី ។



**កញ្ច្រោងចំណី**

ការផ្តល់ចំណីគួរតែបន្ថយ នៅពេលមានចំណីធម្មជាតិក្នុងស្រះគ្រប់គ្រាន់និង ករណីទឹក



ស្រះមានភាពក្រខ្វក់ , ខ្វះអុកស៊ីសែន ដើម្បីរង់ចាំកែលំអគុណភាពទឹកស្រះសិន។ ចំពោះករណីផ្សេងទៀតកំរិតនៃការផ្តល់ចំណីត្រូវបានបង្កើន នៅពេលស្រះខ្សត់ចំណីធម្មជាតិ ។

ជាធម្មតាចំណីត្រូវផល់អោយត្រីចំនួន ២ ដងក្នុងមួយថ្ងៃ នៅពេលព្រឹកបន្ទាប់ពីថ្ងៃរះ ( ម៉ោង៨,៣០-៩,០០ ) ជាពេលដែលមានការបង្កើនបរិមាណអុកស៊ីសែន ក្នុងស្រះដោយពន្លឺព្រះអាទិត្យ និង ពេលល្ងាចម្តង នៅមុនពេលថ្ងៃលិច ។

ជាទូទៅចំណី ត្រូវផ្តល់នៅកន្លែងតែមួយ នៅក្បែរមាត់ស្រះ ដោយដាក់ក្នុងកញ្ច្រោងពន្លិចទឹក ឬ បាចលើផ្ទៃទឹកស្រះ ។

## ៦-ការលូតលាស់

ការលូតលាស់ធំធាត់នៃត្រី អាស្រ័យលើកត្តាជាច្រើន ដូចជា គុណភាពចំណី សីតុណ្ហភាព កត្តាជីវសាស្ត្រ សុខភាពត្រី **ភេទ។ល។**

មជ្ឈដ្ឋានរស់នៅ ជាកត្តសំខាន់ណាស់ដែលជួយជំរុញ ឬ បន្ថយ ដល់ល្បឿនលូតលាស់របស់ត្រីអោយកើន ឬ ថយ អាស្រ័យទៅតាមលក្ខខ័ណ្ឌ អំណោយផល ឬ មិនអំណោយផល ។ ចំណីដែលត្រីស៊ី មិនគ្រាន់តែជួយដល់ការលូតលាស់ សារពាង្គកាយប៉ុណ្ណោះទេ ព្រមទាំងជួយបង្កើនកោសិកាបន្តពូជនិងស្រួបដោយសារធាតុបំរុងសំរាប់ផ្គត់ផ្គង់ក្នុងដំណាក់កាលត្រីពងកូនទៀតផង ។

ត្រីទីឡាព្យានីឡូទីកា លូតលាស់ក្នុងកំរិតសីតុណ្ហភាពពី ១៥-៣០ អង្សា សេ ។ ប៉ុន្តែនៅចន្លោះពី ២៤-២៨ អង្សា សេ ត្រីមានល្បឿនលូតលាស់ឆាប់រហ័ស ។ ឧស្ម័នអុកស៊ីសែនសមស្របមានពី ២-៣មក្រ/លីត្រ។

ចំពោះលក្ខខ័ណ្ឌសីតុណ្ហភាព សមស្រប និង មានចំណីគ្រប់គ្រាន់ក្នុងរយះពេលចិញ្ចឹម ១ឆ្នាំ ត្រីអាចមានទំងន់មធ្យម ៣០០-៤០០ ក្រាម ។



៧-ការបន្តពូជ

ការបន្តពូជជាផ្នែកមួយ នៃលក្ខណៈជីវសាស្ត្ររបស់ត្រីដើម្បីធានាពនូវភាពគង់វង្សនៃពូជរបស់ប្រភេទត្រី ។

ក-លក្ខណៈសំគាល់ត្រីញី ឈ្មោល

ត្រីឈ្មោលក្បាលធំជាងត្រីមេ ព្រុយខ្នង និង ព្រុយកន្ទុយមានពណ៌សម្បុរល្អ នៅពេលត្រីពេញវ័យយើងសង្កេតឃើញសរីរៈបន្តពូជខាងក្រោមានរន្ធពីរ រន្ធ ១ ជារន្ធបន្តពូជ និង រន្ធបញ្ចេញទឹកនោម ឯរន្ធទី ២ ជារន្ធបញ្ចេញចោល ហើយក្រពេញបន្តពូជមានរាងវែងតូចមូល ។

ត្រីមេក្បាលតូចជាងត្រីឈ្មោល ស្បែកខាងក្រោមថ្គាមក្រោម និង ដើមបំពង់ករាងលោចឿក់បន្តិច ព្រុយខ្នង និង ព្រុយកន្ទុយពុំមានពណ៌ស្រស់ដូចត្រីឈ្មោលទេ ឯប្រដាប់បន្តពូជខាងក្រោមានរន្ធ៣ ។ ដោយឡែក

រន្ធ ១ បញ្ចេញទឹកនោម រន្ធ ១ ជារន្ធបន្តពូជ និង រន្ធ១ទៀតជារន្ធបញ្ចេញចោល ។




**ខ-អាយុបន្តពូជ**

ត្រីទីឡាព្យានីឡូទីកា អាចផ្តល់ពងលើកដំបូងពេលចិញ្ចឹមបានអាយុ ៦ ខែ ។



កំលាំងបន្តពូជកាន់តែខ្សោយ កាលណាអាយុត្រីកាន់តែច្រើន ។ ត្រីក៏ដូចមាន់ ទាដែរ កាលណាមាន់មានអាយុតិច ( នៅក្មេង ) អាចផ្តល់ពងបានតិច ឯមាន់ពេញវ័យអាចផ្តល់ពងបានច្រើនបំផុត រីឯមាន់មានអាយុចាស់ផ្តល់ពងបានចំនួនតិចវិញ ។

ទឹកភាក់ជា លក្ខខ័ណ្ឌអំណោយផលល្អដល់ការបន្តពូជរបស់ត្រី ។ ការចិញ្ចឹមក្នុងស្រះ រយៈពេលបន្តពូជ **ពីលើកទី ១ ទៅលើកទី ២** មានរយៈពេល **ពី ៤០-៤៥ ថ្ងៃ** ។

**គ-រដូវបន្តពូជ**

ត្រី *ទីឡាព្យានីឡូទីកា* **អាចបន្តពូជបាន**ពេញមួយឆ្នាំ ប៉ុន្តែលក្ខខ័ណ្ឌអាកាសធាតុនៅប្រទេសយើងការបន្តពូជ បានល្អច្រើននៅរដូវក្តៅ ចាប់ផ្តើមពីខែមេសា ដល់ ខែឧសភា ដែលមានសីតុណ្ហភាពសមស្រប ដល់ការបន្តពូជ ( ២៦-៣០ អង្សា សេ ) ។

### ៨-លក្ខណៈបន្តពូជ

ត្រីទីឡាព្យានីឡូទីកា ជាប្រភេទត្រីរស់នៅតំបន់ក្តៅនៅប្រទេសជាច្រើន ដែលមានអាកាសធាតុក្តៅ និង ក្តៅល្មម គេបាននិយមចិញ្ចឹមត្រីទីឡាព្យានីឡូទីកា ។

**ត្រីទីឡាព្យាអាចបន្តពូជ** នៅក្នុងស្រះ**បានដោយលក្ខណៈធម្មជាតិ** ។

**នៅពេលបន្តពូជត្រីមេឈ្មោល** នាំគ្នាធ្វើ**សំបុកនៅបាតស្រះ** និង នៅតាមជើងទេរស្រះ មានរាងជាបាតខ្ទះ ជំរៅពី ១០-២០ សម និង អង្កត់ផ្ចិតពី ៣០-៤០ សម ។

បើសិនត្រីឈ្មោលពុំអាចធ្វើសំបុក ឬរូងបានទេនោះ(អាងបេតុង) នៅបាតស្រះគួរដាក់ពាង , ឡាំង ឬ ធ្វើប្រអប់ឈើតូចៗ សំរាប់ជាសំបុកអោយត្រីពង ។

ការចាប់ផ្តើមបន្តពូជដំបូងត្រីឈ្មោលនាំ**ត្រីមេស្វែងរកសំបុក** ដោយប្រើកន្ទុយកាយដី**ដែលមានទំហំធំ** ឬ តូច អាស្រ័យដោយ



កំលាំង និងទំហំត្រីឈ្មោល ។ ត្រីមេជំរុះពងទៅក្នុងសំបុក ហើយត្រីឈ្មោលបញ្ចេញ ស្អែមទៅលើពងដើម្បីផ្សំកំណើត ។

ត្រីមេលេបគ្រាប់ពង ដែលផ្សំកំណើតរួចនៅក្នុងមាត់របស់វា រហូតដល់រយៈពេល ២-



៣ថ្ងៃ ក្រោយមកទើបពងចាប់ផ្តើមញាស់ ។ បន្ទាប់មកត្រីមេ ឈ្មោលជាអ្នកការពារសំបុក។

កូនត្រីម្សៅនៅតែរក្សាការជ្រកនៅក្នុងមាត់របស់មេរហូតដល់រយៈពេលប្រមាណ ៧ ថ្ងៃ ទើបអាចចេញរកចំណីដោយខ្លួនឯង ។

នៅពេលមានឧបសគ្គផ្សេង ៗ ត្រីមេប្រមូលពង ឬ កូនបញ្ចូលក្នុងផ្ទក់បំពង់ក ។

ត្រីអាចផ្តល់ ពង ពី ៦-១១ ដង ក្នុង ១ឆ្នាំ ។ត្រីមានបរិមាណពងតិចបើប្រៀបធៀបទៅនឹងពពួកត្រីកាប ។ ប៉ុន្តែកូនត្រីមានអាត្រាគង់វង្សខ្ពស់ ពីព្រោះមេត្រីអាចថែរក្សាកូនបានរហូតដល់កូនអាចរកចំណីបានដោយខ្លួនឯង ។

កំលាំងបន្តពូជរបស់ត្រីទីឡាព្យានីឡូទីកាអាស្រ័យលើទំហំត្រីមេនិងអាយុកាលរបស់ត្រី។

ត្រីមេទំងន់ពី ២០០ - ៣០០ ក្រាម អាចផ្តល់ពង ពី ៣០០-៤០០ គ្រាប់ពង ។

## ៩-ការប្រមូល និង ផ្សាំកូនត្រី

ដួសយកកូនត្រីម្សៅដែលហែលជាហ្វូង។ នៅលើផ្ទៃទឹកស្រះ ដោយប្រើកន្ត្រងស្បៃញឹក។



កូនត្រីអាចដាក់ចិញ្ចឹមបំប៉ននៅតាមស្រះ ឬ នៅតាមស្បៃមុង ក្នុងរយៈពេល ៥-៦ សប្តាហ៍ រហូតដល់កូនត្រីមានប្រវែងដងខ្លួន ២-៣សម ទើបអាចចាប់ដាក់ចិញ្ចឹមតាមស្រះ ឬ លក់បាន ។

កូនត្រីដាក់ផ្សាំបំប៉នទៅតាមទំហំ និង អាយុកាលរបស់វានៅតាមស្រះ ឬ ស្បៃមុង ដើម្បីជៀសវាងត្រី **ដែលមានទំហំធំជាងស៊ីកូនតូចៗ** ។ **កូនត្រីមានអាយុប្រហាក់ប្រហែលគ្នានោះមានអាត្រាគង់វង្សខ្ពស់** ព្រោះពុំអាចស៊ីគ្នាបាន ។

គួរដាក់រាវីរុក្ខជាតិទឹកមួយចំនួននៅតាម**មាត់ស្រះ** ដើម្បីអោយកូនត្រីម្សៅជ្រក និង ងាយស្រួលក្នុងការប្រមូលកូនត្រី ។

កូនត្រីម្សៅហែលលើផ្ទៃទឹកជាហ្វូង ។ ហើយលាក់ខ្លួន នៅតាមគុម្ពរុក្ខជាតិទឹកនានា ដើម្បីជៀសផុតពីត្រីកាចចាប់ជាចំណី ។

ប្រសិនបើយើងពុំបានដួសប្រមូលទេនោះ កូនត្រីភាគច្រើនអាចស្លាប់ ឬ ក៏ត្រូវបានត្រីធំចាប់ស៊ីជាចំណី ។តែទោះជាយ៉ាងណាក៏ដោយ ការចិញ្ចឹមត្រីទីឡាព្យានីឡូទីកា មានអាត្រាគង់វង្សខ្ពស់ ដែលបណ្តាលអោយបរិមាណត្រីនៅក្នុងស្រះមានចំនួនកើនឡើង នាំអោយត្រីមានកំរិតលូតលាស់យឺត ។

## ១០-បញ្ហាសំខាន់ ៗ ដែលជួបប្រទះ

ចំពោះស្រះផលិតពូជត្រីទីឡាព្យា កូនត្រីពូជដែលមានអាយុពេញវ័យហើយ ត្រីនឹងចាប់ផ្តើមបន្តពូជនៅក្នុងស្រះ ដែលនាំអោយបរិមាណត្រីកើនឡើងច្រើនលើសលប់ បណ្តាលអោយត្រីលូតលាស់មិនល្អ ។ ករណីនេះយើងត្រូវចាប់លក់ ឬហូបខ្លះ ដើម្បីរំលោះត្រីក្នុងស្រះ ។

ត្រីមេពូជកំពុងថែរក្សាពង កូនក្នុងមាត់ នោះត្រីពុំមានលទ្ធភាពពេញលេញអាចស៊ីចំណី



 បានទេ ឬព្រោះបណ្តាលអោយត្រីស្គម ជាពិសេសបើស្រះមានត្រីញោលច្រើននោះ វានឹងដេញរំខាន ។

បញ្ហាដែលទាក់ទងដល់ ការបន្តពូជឆាប់រហ័សរបស់ត្រីទីឡាព្យា នោះអាចការពារតាមវិធីសាស្ត្រដូចខាងក្រោម :

ដាក់ត្រីកាចបញ្ចូលទៅក្នុងស្រះអោយស៊ីរំលោះកូនត្រីតូចៗ ដើម្បីជៀសវាងការចង្អៀតក្នុងស្រះ ដែលបណ្តាលអោយត្រីមានការលូតលាស់យឺត ។

ការដាក់ត្រីកាចក្នុងស្រះ មិនត្រូវដាក់ត្រីមានទំហំធំពេកទេ ព្រោះអាចបណ្តាលអោយស៊ីត្រីធំបាន។

## ១១-ការគ្រប់គ្រង និង ថែទាំស្រះ

-ត្រួតពិនិត្យការជ្រាបទឹកតាមភ្លឺស្រះ

-ប្រុងប្រយ័ត្នការពារកុំអោយ ពពួកសត្វកុក ពស់ កង្កែប អណ្តើក កណ្តុរ ឬត្រីកាច

ចូលស៊ីត្រីចិញ្ចឹម ។

-ពិនិត្យសុខភាពត្រី និង ចរឹកស៊ីចំណី ជាប្រចាំ ។



-ពិនិត្យតម្រង និង ប្រព័ន្ធលូទឹក

-សំអាត និង បំបាត់រុក្ខជាតិចង្រៃ



-រក្សាកំរិតកំពស់ទឹកអោយបានគ្រប់គ្រាន់ ដោយមានជំរៅមិនរាក់ជាង ១ ម៉ែត្រ ។






-កសិករត្រូវពិនិត្យស្រះជានិច្ចកាល និង ធ្វើអោយប្រសើរឡើង ពេលដែលបរិមាណ អុកស៊ីសែនមានកំរិតទាប ពិសេសនៅពេល ថ្ងៃទើបរះ ។

ករណីទឹកស្រះ មានពណ៌បៃតងចាស់ បណ្តាអោយរស្មីសំយោគពុំដំណើរការល្អ និង

ខ្លះអុកស៊ីសែន ។ យើងគប្បីផ្អាកការដាក់ជី និងចំណីបន្ថែម ដោយបង្ហូរទឹកចេញខ្លះហើយ បញ្ចូលទឹកថ្មីបន្ថែមវិញ ។

## ១២-ការប្រមូលផល

ការប្រមូលផលគួរតែធ្វើ នៅពេលមានធាតុអាកាសត្រជាក់ដោយបញ្ឈប់ការផ្តល់ចំណីចំនួន ១-២ ថ្ងៃ មុនពេលប្រមូលផល ។



ការប្រមូលផល



ការប្រមូលផលនៅពេលចិញ្ចឹមបានរយៈពេលពី ៨- ១០ ខែ ។

ការប្រមូលផលដោយប្រើសំណាញ់ ឬ អួនអូស ។

ត្រូវជ្រើសរើសត្រីមេពូជ សំរាប់ដាក់ចិញ្ចឹមក្នុងស្រះនៅឆ្នាំបន្តទៀត ។

ក្រោយពេលប្រមូលផលរួចត្រូវប្រញាប់ប្រញាល់ រៀបចំសំអាតស្រះឡើងវិញមុនដាក់កូនត្រីចិញ្ចឹមសារឡើងវិញ ។

## ឯកសារយោង

-Tran Van Quynh – 1980 -លក្ខណៈជីវសាស្ត្រ និង បច្ចេក ទេសចិញ្ចឹមត្រីទីឡាព្យា

-Le Van Dang – 1967 -វិធីសាស្ត្រចិញ្ចឹមត្រីទីឡាព្យានីឡូទិកាក្នុងស្រែ

-Lydia A. Brown –1996 – ការចិញ្ចឹមត្រីអោយមានសុខភាពល្អនៅក្នុងប្រទេសកម្ពុជា

## សមាសភាពគណៈកម្មការអភិវឌ្ឍន៍វារីវប្បកម្មខេត្តតំបន់ខាងជើង

| ល.រ | នាមគោត្តនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១ | ព្រិន សារិន | ជលផល សៀមរាប | ប្រធាន |
| ២ | ភុំ រិមល | ជលផល ពោធិសាត់ | អនុប្រធាន |
| ៣ | សាត ពៅ | ជលផលបន្ទាយមានជ័យ | ហិរញ្ញិក |
| ៤ | ឯម វរិទ្ធ | ជលផល បាត់ដំបង | ទីប្រឹក្សា |
| ៥ | អៀច ធា | កសិកម្ម CARERE | ទីប្រឹក្សា |
| ៦ | អ៊ុង រចនា | នាយកដ្ឋានជលផល | សមាជិក |
| ៧ | លី គួង | នាយកដ្ឋានជលផល | សមាជិក |
| ៨ | ជុក ចន្ទា | ជលផល ពោធិសាត់ | សមាជិក |
| ៩ | ឆេង វិបុលរិទ្ធ | ជលផល សៀមរាប | សមាជិក |
| ១០ | ភឿក សាង | ជលផល បាត់ដំបង | សមាជិក |
| ១១ | លី វេង | ជលផលបន្ទាយមានជ័យ | សមាជិក |
| ១២ | សៀវ សៅភាក្យ | ជលផល បាត់ដំបង | សមាជិក |